SLEUK RITH INSTITUTE
A Permanent Documentation Center of Cambodia
66 Preah Sihanouk Blvd | Phnom Penh
+855 23 21 18 75 | www.cambodiasri.org

# ការអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា

## វគ្គបណ្តុះបណ្តាលគ្រូបង្រៀន
## ស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

## មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ខេត្តបាត់ដំបង
## ថ្ងៃទី១០ ដល់ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦

## សេចក្តីប្រកាសព័ត៌មាន

មជ្ឈមណ្ឌលឯកសារកម្ពុជា/វិទ្យាស្ថានស្លឹករឹត និងក្រសួងអប់រំ យុវជន និងកីឡា មានកិត្តិយសសូមប្រកាសបើកវគ្គបណ្តុះបណ្តាលគ្រូបង្រៀនលើកទី១៦ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ខេត្តបាត់ដំបង ចាប់ពី*ថ្ងៃទី១០ដល់១៤ ខែតុលា ឆ្នាំ២០១៦* ដល់គ្រូបង្រៀនចំនួន១០០នាក់ មកពីខេត្តបាត់ដំបង ពោធិ៍សាត់ ឧត្តរមានជ័យ បន្ទាយមានជ័យ និង ប៉ៃលិន។ វគ្គនេះ នឹងផ្តល់នូវការបង្ហាត់បង្រៀនពីមាតិកាប្រវត្តិសាស្ត្រ និងវិធីសាស្ត្របង្រៀន ព្រមទាំងផ្តល់នូវសម្ភារៈបង្រៀនដ៏សម្បូរណ៍បែប ដល់គ្រូបង្រៀន ដើម្បីលើកកម្ពស់ការបង្រៀនរបស់ខ្លួននៅតាមវិទ្យាល័យរៀងខ្លួន។ ការអភិវឌ្ឍន៍ចំណេះដឹងនេះ គឺសំខាន់ណាស់ក្នុងការលើកកម្ពស់ឲ្យមានការកសាងសន្តិភាព ការផ្សះផ្សាជាតិ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍។

បច្ចុប្បន្ននេះ កម្ពុជាទទួលស្គាល់ពីសារៈសំខាន់នៃការអប់រំ ថាជាដំណើរដ៏វែងឆ្ងាយមួយឆ្ពោះទៅរកការការពារ ការព្យាបាលរបួសផ្លូវចិត្ត ការកសាងសន្តិភាព និងការផ្សះផ្សាជាតិ។ ហេតុដូច្នេះហើយ ទើបមជ្ឈមណ្ឌលឯកសារកម្ពុជា /វិទ្យាស្ថានស្លឹករឹត និងក្រសួងអប់រំ យុវជន និងកីឡា ធ្វើការសហការគ្នាដើម្បីផ្តល់នូវវគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀនប្រវត្តិវិទ្យា ភូមិវិទ្យា អក្សរសាស្ត្រខ្មែរ និងសីលធម៌-ពលរដ្ឋ ជាង៣ពាន់នាក់រួចមកហើយ ចាប់តាំងពីឆ្នាំ២០០៩មក។ ដើម្បីពង្រឹងការយល់ដឹងដ៏មានប្រសិទ្ធិភាពពីកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍បន្ថែមទៀត មជ្ឈមណ្ឌលឯកសារកម្ពុជាបានអភិវឌ្ឍន៍កម្មវិធីសិក្សា និងបានផ្តល់ការអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការអប់រំពីអំពើប្រល័យពូជសាសន៍ ដល់សង្គមស៊ីវិល និងរាជរដ្ឋាភិបាល រួមទាំងសាកលវិទ្យាល័យ សាលាបណ្ឌិតសភានគរបាល សាលាហ្វឹកហ្វឺនមន្ត្រីកងរាជអាវុធហត្ថ និងវិទ្យាស្ថានជាតិ អប់រំ។ លើសពីនេះទៀត មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា បានចាប់ផ្តើមកម្មវិធីថ្មីពីរទៀត ដើម្បីបណ្តុះបណ្តាលគរុសិស្ស-និស្សិតនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៦គឺ តាកែវ រាជធានីភ្នំពេញ កំពង់ចាម កណ្តាល បាត់ដំបង និងព្រៃវែង និង

បង្ហាត់បង្រៀនដល់សិស្សកម្រិតវិទ្យាល័យក្នុងទូទាំងរាជធានីភ្នំពេញ ពីសារៈសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

ក្រោមជំនួយទ្រទ្រង់ទាំងស្រុងពីសហគមន៍អឺរ៉ុប តាមរយៈការិយាល័យអង្គការសហប្រជាជាតិសម្រាប់សេវាគម្រោង ចំពោះវគ្គបណ្តុះបណ្តាលគ្រូកម្រិតមូលដ្ឋាន និងវគ្គបណ្តុះបណ្តាលគ្រូកម្រិតឧត្តម វគ្គបណ្តុះបណ្តាលគ្រូបង្រៀនលើកទី១៦នេះ មិនត្រឹមតែផ្តល់ដល់គ្រូបង្រៀន ពីការយល់ដឹងស៊ីជម្រៅទៅលើមាតិកាប្រវត្តិសាស្ត្រ និងវិធីសាស្ត្របង្រៀនថ្មីទំនើបៗ ក៏ដូចជាការលើកកម្ពស់ពីការយល់ដឹងនិងការអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបង្រៀនអ្នកទាំងនោះ ឲ្យយល់ដឹងពីសារៈសំខាន់នៃការគោរពគោលការណ៍សិទ្ធិមនុស្សជាសកលទៀតផង។

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖*

**ផេង ពង្សរ៉ាស៊ី**

អ្នកសម្របសម្រួល គម្រោងស្តីពីការអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា

ទូរស័ព្ទ៖ ០១២ ៦៩ ៦៩ ៦១

អ៊ីមែល៖ truthrasy.p@dccam.org